# ព្រះគម្ពីរ ពិសេស



ដោយ ជូលៀ វីលីដសិន
( ផ្អែកទៅលើដំណើររឿងពិត )

ប៉ែរនីសបាននិយាយថា « ប៉ា ដល់វេនប៉ាអានហើយ » ។ នាងបានបើកព្រះគម្ពីរ ។ ម៉ាក់ និងប៉ាអង្គុយនៅជិតនាងនៅលើសាឡុង ។

ប៉ា។បានអានខគម្ពីរដំបូង ។ ប៉ែរនីស បាននិយាយថា « ខ្ញុំដឹងថាទ្រង់ស្រឡាញ់បុត្រាបុត្រីរបស់ទ្រង់ ។

ខ្ញុំដឹងថាទ្រង់ស្រឡាញ់បុត្រាបុត្រីរបស់ទ្រង់ » ។

ប៉ា។ បាននិយាយថា « ទោះជាយ៉ាងណាក្តី ប៉ាមិនដឹងពីអត្ថន័យទាំងអស់នោះទេ » ។*

*ទោះជាយ៉ាងណាក្តី* គឺជាពាក្យដ៏លំបាក ។ ប៉ែរនីស មិនអាចអាននៅឡើយទេ ហើយនាងមិនយល់ពីអត្ថន័យពាក្យទាំងអស់ទេ ។ ប៉ុន្តែនាងចូលចិត្តចាតាមពាក្យនោះនៅពេលគ្រួសាររបស់នាងអានព្រះគម្ពីរជាមួយគ្នា ។

នៅថ្ងៃស្អែកនៅពេលអានព្រះគម្ពីរ ប៉ាមានអ្វីដែលគួរឲ្យភ្ញាក់ផ្អើលមួយ ។ គាត់បានមានប្រសាសន៍ថា « ប៉ាមានអ្វីមួយពិសេសឲ្យកូន » ។ គាត់បានឲ្យព្រះគម្ពីរមួយក្បាលទៅប៉ែរនីស ។ ព្រះគម្ពីរនោះមានរូបភាពមនុស្ស និងទូកនៅខាងមុខ ។

« តើព្រះគម្ពីរនេះសម្រាប់កូនមែនទេ ? » ប៉ែរនីស បានសួរ ។ នាងឱបព្រះគម្ពីរធំនេះនៅក្នុងដៃនាង ។

ប៉ាបានតបថា « សម្រាប់កូន » ។ « មើលខាងក្នុងមើល » ។

ប៉ែរនីសបានបើកព្រះគម្ពីរនេះ ។ ភ្នែករបស់នាងបានបើកធំ។ ។ មានរូបភាពដែលមានពណ៌ជាច្រើននៅក្នុងនោះ ។

« តើព្រះគម្ពីរនេះឈ្មោះអ្វីទៅ ? » ប៉ែរនីស បានសួរ ។

ប៉ា។បានចង្អុលទៅពាក្យនៅខាងលើនោះ ។ គាត់បានមានប្រសាសន៍ថា « *ដំណើររឿងព្រះគម្ពីរមរមន* » ។

ប៉ែរនីសបានអានពាក្យនៅលើក្របនោះ ។ នាងបាននិយាយថា « ដំណើររឿងព្រះគម្ពីរមរមន » ។

ម៉ាក់បានមានប្រសាសន៍ថា « ព្រះគម្ពីរនេះមានដំណើររឿងដូចគ្នានឹងអ្វីដែលយើងអាននៅក្នុងព្រះគម្ពីរ » ។

ប៉ែរនីសបានចង្អុលទៅរូបភាពនេះ ។ នាងបានសួរថា « តើនោះជានរណា ?

« អឺ ។ តើកូនឃើញធ្នូ និងផ្លែព្រួញទេ ? » ម៉ាក់បានសួរ ។

ប៉ែរនីស បានងក់ក្បាល ។

« តើកូននៅចាំការអានអំពីនរណាម្នាក់ដែលមានធ្នូបាក់ដែរឬទេ ? ប៉ា។បានសួរ ។

« នីហ្វៃ ? » ប៉ែរនីសបានឆ្លើយ

ប៉ា។បានមានប្រសាសន៍ថា « បាទ គឺនីហ្វៃ » ។

ប៉ែរនី បានញញឹម ។ « អរគុណប៉ា។ ។ អរគុណម៉ាក់ ។ កូនចូលចិត្តព្រះគម្ពីរនេះណាស់ » ។

រាល់យប់ ប៉ែរនី អានព្រះគម្ពីររបស់នាងជាមួយម៉ាក់ និងប៉ា ។ នាងបានចង្អុលទៅរូបភាពនេះ ។ នាងរៀននិយាយពាក្យពិបាក។ ។ ហើយនាងរៀនអានពាក្យស្រួល។ដោយខ្លួននាង !

ការអានព្រះគម្ពីរធ្វើឲ្យនាងមានអារម្មណ៍សប្បាយរីករាយ ។ នាងសប្បាយចិត្តដែលនាងអាចអានព្រះគម្ពីរជាមួយម៉ាក់ និងប៉ា ! ●

*ដំណើររឿងនេះកើតឡើងនៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ។*

* *នីហ្វៃទី ១ ១១:១៧*